ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

ភ្នំពេញ ថ្ងៃទី០៤ ខែ[illegible] ឆ្នាំ ២០១៧

លេខៈ 227 កបទ.សអ.បល

# សេចក្តីជូនដំណឹង

សូមជូនដំណឹងដល់សាធារណជនឲ្យបានជ្រាបថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីក្របខណ្ឌ "ក" ចំនួន ១៦ នាក់ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ សៅរ៍ ទី ១៧ ខែ មិថុនា ឆ្នាំ ២០១៧ ដូចខាងក្រោមៈ

បេក្ខជន-បេក្ខនារី ត្រូវមានលក្ខណៈសម្បត្តិដូចតទៅៈ

១. មានសញ្ញាបត្រចាប់ពី**បរិញ្ញាបត្រ**ឡើងលើមុខជំនាញៈ ភាសាបរទេស ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ សេដ្ឋកិច្ច គណនេយ្យ ពាណិជ្ជសាស្ត្រ និងព័ត៌មានវិទ្យា

២. មានចំណេះដឹងភាសាបរទេសច្បាស់លាស់

៣. មានសញ្ជាតិខ្មែរ និងសុខភាពល្អ

៤. អាយុៈ

- មិនលើស ៣៥ឆ្នាំ សម្រាប់សញ្ញាបត្របរិញ្ញាបត្រ (គិតត្រឹមថ្ងៃប្រឡង)
- មិនលើស ៤០ឆ្នាំ សម្រាប់សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ (គិតត្រឹមថ្ងៃប្រឡង)
- មិនកំណត់អាយុសម្រាប់សញ្ញាបត្រថ្នាក់បណ្ឌិត

៥. ជនពិការ ដែលមានសមត្ថភាពសមស្រប និងបេក្ខនារី ត្រូវបានលើកទឹកចិត្ត ។

<u>បញ្ជាក់</u> ៖ - សញ្ញាបត្រពីក្រៅប្រទេស ត្រូវបញ្ជាក់ពីនាយកដ្ឋានឧត្តមសិក្សា
- សញ្ញាបត្រក្នុងប្រទេស ត្រូវបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន
- បេក្ខជន-នារី ត្រូវបំពេញសំណុំបែបបទៈ ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសមន្ត្រី ចំនួន ០១ ច្បាប់ ជីវប្រវត្តិសង្ខេប ចំនួន ០១ ច្បាប់ សលាកប័ត្រឯកត្តជន ០១ ច្បាប់ និងបង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង ចំនួន ០១ ច្បាប់

- ត្រូវបញ្ជាក់អំពីភាពគ្មានទោស (លិខិតថ្កោលទោស) ពីក្រសួងយុត្តិធម៌ និងលិខិតបញ្ជាក់អំពីសុខភាពពីមន្ទីរពេទ្យរដ្ឋបន្ទាប់ពីបេក្ខជន-បេក្ខនារី ប្រឡងជាប់ជាស្ថាពរ
- ការដាក់ពាក្យប្រឡងតម្រូវឲ្យបង់ប្រាក់ចំនួន ២០.០០០ រៀល ។

វិញ្ញាសាប្រឡង ៖

វិញ្ញាសាសរសេរ និងវិញ្ញាសាសួរផ្ទាល់មាត់៖ ភាសាអង់គ្លេស បារាំង ជប៉ុន កូរ៉េ ចិន ឡាវ ថៃ ឬ វៀតណាម។

សាធារណជន ដែលមានបំណងចូលរួមប្រឡង សូមទាញយក និងបំពេញសំណុំបែបបទសុំសិទ្ធិប្រឡងតាមរយៈគេហទំព័រក្រសួង www.mfaic.gov.kh និងទំព័រហ្វេសប៊ុកក្រសួង www.facebook.com/mfaic.gov.kh។

ការទទួលពាក្យ នឹងត្រូវចាប់ផ្តើមពីថ្ងៃទី **២១ ខែ មេសា** រហូតដល់ថ្ងៃទី **២២ ខែ ឧសភា ឆ្នាំ ២០១៧** រៀងរាល់ម៉ោងធ្វើការ នៅនាយកដ្ឋានបុគ្គលិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានអាសយដ្ឋានអគារលេខ ៣ វិថី **សម្តេច ហ៊ុន សែន** សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

បញ្ជាក់៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានសិទ្ធិជម្រុះបេក្ខជន-បេក្ខនារី ដែលមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ មិនអោយចូលរួមប្រឡង។

**ជ. រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**អ៊ុច បូរិទ្ធ**

ចម្លងជូន:
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ឯកសារ - កាលប្បវត្តិ